002/19-09-2007-ECCC/TC
E1/104

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 08 / 2012
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ០៨ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៨២

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី សែ កុលវុឌ្ឍី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាវុស្សី, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW , លោកAndrew IANUZZI |

| | |
|---|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS | |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta Guisse | |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក Ferdinand Djammen Nzepa, លោកស្រី ម៉ុច សុវណ្ណារី, លោក ឡោ ជុនធី, លោក សំ សុគង់, លោកស្រី ស៊ិន សុវន, លោកស្រី Marie GUIRAUD, លោកស្រី ជេត វណ្ណលី, លោក វ៉ែន ពៅ | |
| សាក្សី៖ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន (TCW-694), សាក្សី អុង ថុងហឿង (TCW-490) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ | |
| ផ្សេងៗ៖ លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី សួង ស៊ីគឿន), កញ្ញា Sonia MESSAOUDI | |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្ដី អៀង សារី<br>មេធាវីការពារក្ដី នួន ជា | ០៩.០៣<br>១២.០៣ | ០៩.០៥<br>១២.០៧ |
| សេចក្ដីសម្រេចទាក់ទងនឹងសំណើសុំដាក់ឯកសារថ្មីរបស់មេធាវីការពារក្ដី នួន ជា ក្នុងការ សួរដេញដោលសាក្សី TCW-490 (E172/27/3) | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ០៩.០៥ | ០៩.០៧ |
| ការបន្តតាំងសំណួរទៅ សាក្សី សួង ស៊ីគឿន ហៅ គង់ ឬ ធន (TCW-694) | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៨<br>០៩.១៨<br>១០.៥៣ | ០៩.១៨<br>១០.៣០<br>១២.០០ |

| | | | |
|---|---|---|---|
| សេចក្តីសម្រេចលើសំណើសុំរបស់សាក្សី TCW-694 ក្នុងការសម្រាកនៅពេលរសៀល និងថ្ងៃស្អែក និងបន្តសវនាការវិញនៅថ្ងៃចន្ទ | អង្គជំនុំជម្រះ | ១២.០១ | ១២.០៣ |
| ការបន្តតាំងសំណួរទៅ សាក្សី អ៊ុង ជុងហៀង (TCW-490) | សហព្រះរាជអាជ្ញា | ១៣.៣៥ | ១៥.៥៧ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ (ជនជាប់ចោទ អៀង សារី សម្រាប់រយៈពេលពេញមួយថ្ងៃ ហើយជនជាប់ចោទ នួន ជា សម្រាប់សវនាការនៅរសៀល) ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ទាក់ទងនឹងការប្រើប្រាស់ឯកសារថ្មីក្នុងអំឡុងពេលសួរដេញដោលសាក្សី</u>** <u>TCW-490 ( E172/27/3)</u>

អង្គជំនុំជម្រះបានបដិសេធសំណើសុំរបស់មេធាវីការពារក្តី នួន ជា។ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ម្តងហើយម្តងទៀតថា សំណើសុំដាក់ភស្តុតាងថ្មីដែលអនុលោមតាមវិធាន៨៧(៤) ត្រូវធ្វើឱ្យបានទាន់ពេលវេលានៅពេលដែលឯកសារថ្មីណាមួយមានពាក់ព័ន្ធទៅនឹងសាក្សីណាម្នាក់ ភាគីត្រូវតែស្នើសុំដាក់ឯកសារនេះឱ្យបានពីរសប្តាហ៍មុនពេលសាក្សីនោះផ្តល់សក្ខីកម្ម ដើម្បីឱ្យអង្គជំនុំជម្រះមានពេលវេលាពិចារណា ដូចដែលអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់នៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E128។ មេធាវីការពារក្តីជនជាប់ចោទ នួន ជា ទើបតែបានដាក់សំណើនេះនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ ពោលគឺមិនបានដល់១មួយសប្តាហ៍ផង មុនពេលសាក្សីដែលមានរហស្សនាម TCW-490 គ្រោងនឹងមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ មេធាវីការពារក្តីជនជាប់ចោទ នួន ជា មិនបានពន្យល់ថាតើនៅពេលណា និងតាមមធ្យោបាយអ្វីដែលខ្លួនបានរកឃើញឯកសារនេះឡើយ ហើយក៏មិនបានវិភាគថាតើអ្វីដែលបានរារាំងដល់ការស្វែងរកឯកសារនេះ តាំងពីពេលដំបូងៗមកនោះទេ។

**<u>ការបន្តតាំងសំណួរទៅសាក្សី សួង ស៊ីគឿន ហៅ គង់ ឬ ធន</u>** <u>(TCW-694)</u>

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្ត និងបញ្ចប់ការតាំងសំណួរទៅសាក្សី។ បន្ទាប់មក អង្គជំនុំជម្រះ

និង មេធាវីការពារក្ដីលោក ខៀវ សំផន បានតាំងសំណួរទៅសាក្សី។

**<u>សេចក្ដីសម្រេចលើសំណើរបស់សាក្សី</u>** <u>TCW-694</u> **<u>សុំសម្រាកនៅសវនាការពេលរសៀល និងបន្ដសវនាការនៅថ្ងៃចន្ទ</u>**

អង្គជំនុំជម្រះបានទទួលយកសំណើរបស់សាក្សី សុំសម្រាកនៅពេលរសៀលនេះ និងថ្ងៃស្អែកពេញមួយថ្ងៃ។ ការស្ដាប់សក្ខីកម្មរបស់សាក្សីនឹងបន្ដធ្វើនៅថ្ងៃចន្ទ ទី ១៣ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩ព្រឹក។

**<u>ការតាំងសំណួរទៅសាក្សី អុង ថុងហឿង</u>** <u>(TCW-490)</u>

សហព្រះរាជអាជ្ញាបានបន្ដ និងបញ្ចប់ការតាំងសំណួរទៅសាក្សី អុង ថុងហឿង។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្ដុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/99 | 6.2 | 00072400-00072407<br>00244274-00244278<br>00611566-00611570 | ពិនិត្យការក្ដាប់ និងអនុវត្តមាគ៌ានយោបាយ ប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិប្រជាធិតេយ្យរបស់បក្ស (ឯកសារទី៦)<br>About governing and carryngout the policy of gathering force of Democratic National Front of party (6th document)<br>About governing and carryngout the policy of gathering force of Democratic National Front of party (6th document) | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/113 | 12.3 | S 00704555-00704568 00280539-00280546 S 00000062-00000078 | [Partial T.] ទីភ្នាក់ងារសារព័ត៌មានកម្ពុជាចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៤ "RENMIN Ribao ទទួលស្វាគមន៍គណៈប្រតិភូនៃរណៈសិរ្សរួបរួមជាតិកម្ពុជា(FUNK) និងរាជរដ្ឋាភិបាលកម្ពុជា(GRUNK)" [Partial T.] Agence Kampuchea d'Information dated 2-April-1974 "RENMIN Ribao of Peking greets the FUNK and GRUNK delegation" Agence Kampuchea d'Information daté 2-apvil-1974 "RENMIN Ribao de Peking salue la delegaton du FUNK et GRUNK" | P | 00000065-73 | | |
| E3/97 | D141/1 | 00270680-00270707 00287097-00287112 00241881-00241896 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុង ថុងហឿង [Surrogate Sheet] Written Record of Interview of ONG Thong Hoeung [Feuille remplacée] Procès verbal d'audition de ONG Thong Hoeung | P | 00270685-86 | 00287100 | 00241884 |
| E3/550 | 20.4 | 00291035-00291038 00087603-00087604 00698732-00698734 | សម្ភាសន៍ជាមួយ អៀង សារី Interview with IENG Sary Interview avec IENG Sary | P | 00291036 | 00086003 | 00698733 |
| E3/1713 | D141/1.2 | 00659077-00659085, 00831062-00831320 00785742-00785882, 00657418-00657425 00287879-00288154 | [Partial T.] ឧបសម្ព័ន្ធ ២៖ សៀវភៅនិពន្ធដោយលោក អុង ថុងហឿង មានចំណងជើងថា "ត្រលប់មើលក្រោយវិញនៃរឿងដ៏សែនខ្លោចផ្សាមួយ" [Partial T.] Annex 2: Book by ONG Thong Hoeung entitled "J'ai cru aux Khmers rouges: Retour sur une illusion" Annexe 2: Livre écrit par ONG Thong Hoeung intitulé "J'ai cru aux Khmers rouges: Retour sur une illusion" | P | 00831090-91 | | 00287910-11 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- **អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០៣) និង នួន ជា (១២.០៦) ចូលរួម**

ដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

- អង្គជំនុំជម្រះ បានសម្រេចបដិសេធលើសំណើសុំរបស់មេធាវីការពារក្ដី នួន ជា ក្នុងការដាក់ឯកសារថ្មីសម្រាប់សួរដេញដោលសាក្សី TCW-490 ។ សំណើសុំនេះដាក់មិនទាន់ពេលវេលា និងមិនមានភាពពាក់ពន្ធ័និងអង្គហេតុដែលកំពុងធ្វើសវនាការ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលដល់សាក្សី សួង ស៊ីគៀន ហៅ គង់ ហៅ ធន ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការវិញនៅម៉ោង ០៩ ព្រឹក ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលដល់សាក្សី អុង ថុងហឿង ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់ មកកាន់បន្ទប់សវនាការវិញនៅម៉ោង ០៩ ព្រឹក ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ និងបង្គាប់ឱ្យនាំសាក្សី សួង ស៊ីគៀន មកកាន់បន្ទប់សវនាការវិញនៅម៉ោង ០៩ ព្រឹក ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ០៩ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សេ កុលវុទ្ធី** Matteo CRIPPA